# ផ្ការីកឥតរុះរោយ

(បទពាក្យ៧)

ឱះឱ!កុលាបរីកស្រស់ខ្ចី
ល្អល្អះប្រិមប្រិយគ្រប់ស្រទាប់
គយគន់កាលណាចិន្ដាជាប់
ចង់យកមកផ្ដាប់នៃបនាសា។
ឆោមអ្នកមានលក្ខណ៍ថ្វាផ្ទូរផង់
ត្រចះត្រចង់លង់នេត្រា
ជាទីប៉ុនប៉ងនៃភមរា
ស្រូបក្លិនក្រេបផ្កាសុខហឫទ័យ។
ឱផ្កាកុលាបប្រៀបវិជ្ជា
ភមរាដូចគ្នានឹងយុវវ័យ
ប្រាថ្នាវិជ្ជាឧត្ដមថ្លៃ
សាងភ័ព្វនិស្ស័យច្នៃជីវិត។
ក្លិនផ្កាកុលាបក្រអូបសាយ
ភមរាសប្បាយបាននៃបនិត្យ
ឯក្លិនវិជ្ជាក្រអូបស្អិត
ដក់ដាមជាប់ចិត្តជនជិតឆ្ងាយ។
វិជ្ជាផ្លូវលោកជ្រកផ្លូវធម៌
អាចរំលេចពណ៌ល្អឆើតឆាយ
ផ្លូវធម៌ស្ងប់ចិត្តចាកអបាយ
ផ្លូវលោកដោះស្រាយខ្សែជីវិត។
វិជ្ជានាំខ្ពស់យសសិរី
មានប្រជាប្រិយល្អប្រណីត
ក្លិនក្លែបសុះសាយទាំងឆ្ងាយជិត
គន្ធាមានឫទ្ធិ៍ហើរច្រាសខ្យល់។
បំភ្លឺជីវិតផុតអន្ធការ
បង្កើតបញ្ញាថ្លានិមល
អាចផ្ចាញ់ឧបសគ្គផុតកង្វល់
នាំប្រាណបានដល់ត្រើយមលំនៅ។
សោភ័ណវិជ្ជាល្អឥតខ្ចោះ
មានហើយរីកស្រស់ឥតហ្មងសៅ
សម្រស់ត្រកាល ត ពង្សផៅ
រីករះឆ្អិនឆ្អៅថ្កើងជីវិត។
នាមជាយុវវ័យលៃអោយច្បាស់
កុលាបល្អល្អះតែងក្រៀមស្វិត
ឯផ្កាវិជ្ជាស្រស់ប្រណីត
លំអជីវិតឥតរុះរោយ។✍

*(១២ មករា ១៩៩៩)*

*ភិក្ខុ ស្វាត សាលឿម*